**Declassified to Public**
**06 September 2012**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | |
|---|---|
| **សំណុំរឿងព្រហ្មទណ្ឌលេខ៖** | ០០២/១៩-០៩-២០០៦-អ.វ.ត.ក-ការិយាល័យសហព្រះរាជអាជ្ញា -75-C14 |
| **លេខស៊ើបសួរ៖** | ០០១/១៨-០៧-២០០៧ |
| **ឈ្មោះសំណុំរឿង៖** | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ កក្កដា ២០០៧ |
| **បញ្ជូនទៅ៖** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទនៃការបញ្ជូន៖** | ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ |
| **ភាគីបញ្ជូន៖** | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម៖** | ភាសាអង់គ្លេស |
| **ប្រភេទឯកសារ៖** | ជាសាធារណៈ |

---

**សេចក្តីជូនដំណឹងរបស់ការិយាល័យសហព្រះរាជអាជ្ញាស្តីពីការផ្ទេរសិទ្ធិអំណាច**
**អនុលោមតាមវិធាន ១៣.១ និង ១៣.៤ នៃវិធានផ្ទៃក្នុង**

---

**បញ្ជូនដោយ៖**

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT

**បញ្ជូនទៅ៖**

**ចៅក្រមនៃអង្គបុរេជំនុំជម្រះ៖**
លោក ប្រាក់ គឹមសាន
លោក ហ្នួត វុទ្ធី
លោក Rowan DOWNING
លោក ប៉ែន ពេជ្រសាលី
លោកស្រី Katinka Lahuis

មេធាវីការពារក្តី៖
លោក ការ សាវុត្ថ
លោក Françcois ROUX

ORIGINAL DOCUMENT
RECEIVED ON 15/11/2007
AT 10:41' BY
NUP SOTHUNVICHET
VICHET
ACTING CASE FILE OFFICER

សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា
ស្តីពីការផ្ទេរសិទ្ធសម្រាប់ពេលសវនាការផ្ទាល់មាត់

**បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម**
**Certified Copy/Copie Conforme**
**ថ្ងៃទី(On/Le)** 16 **ខែ(Month/Mois)** NOV
**ឆ្នាំ (Year/Année)** 2007
**ក្រឡាបញ្ជី/ Greffier** NUP SOTHUN VICHET

00152592



## អំពីប្រវត្តិនៃនីតិវិធី

១. នៅថ្ងៃទី២០ និង២១ ខែវិច្ឆិកាឆ្នាំ២០០៧ សវនាការជាសធារណៈមួយត្រូវបានធ្វើឡើងតាមពេលកំណត់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ទាក់ទងអំពីបណ្ដឹងឧទ្ធរណ៍តវ៉ាចំពោះដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតលើរូបឈ្មោះ កាំង ហ្កេចអ៊ាវ (ជនត្រូវចោទ) ។ ការណែនាំអំពីការបើកសវនាការគឺត្រូវបានគ្រោងធ្វើនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ខាងមុខនេះ ដោយសម្ងាត់ ។ សហព្រះរាជអាជ្ញាត្រូវបានកោះអញ្ជើញឲ្យចូលរួមនៅក្នុងគ្រប់កាលបរិច្ឆេទកំណត់ទាំង៣ ដែលជាសវនាការជាសាធារណៈជាលើកទី១ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។

២. សហព្រះរាជអាជ្ញា មានបំណងថា ការតស៊ូមតិដោយផ្ទាល់មាត់នៅក្នុងគ្រប់សវនាការទាំងអស់របស់ខ្លួនទោះបីធ្វើជាសាធារណៈៈឬ*ជាសម្ងាត់*ក្ដី គឺនឹងត្រូវធ្វើឡើងមិនគ្រាន់តែដោយខ្លួនឯងផ្ទាល់ប៉ុណ្ណោះទេ ក៏ប៉ុន្តែជួនកាលតាមការចាំបាច់របស់ការិយាល័យសហព្រះរាជអាជ្ញា ឬតាមការតម្រូវនៃលក្ខណៈស្មុគ្រស្មាញរបស់រឿងក្ដី គឺធ្វើដោយព្រះរាជអាជ្ញារងមួយ ឬច្រើនរូបរបស់ខ្លួន ជំនួយការជាន់ខ្ពស់ និងបុគ្គលិកជំនួយការព្រះរាជអាជ្ញា។

## អំពីច្បាប់

៣. មាត្រា២២(ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ច្បាប់ស្ដីពី អ.វ.ត.ក)[1] ចែងដូចខាងក្រោមនេះ៖
"ព្រះរាជអាជ្ញាមួយរូបៗមានសិទ្ធ ដើម្បីជ្រើសរើសព្រះរាជអាជ្ញារងមួយរូប ឬច្រើនរូប ដើម្បីជួយខ្លួនក្នុងការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះ ។"

---

[1] ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា-ឯកសារតុលាការ។

00152593



៤. វិធាន១៣(១)នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក[2] ចែងដូចតទៅនេះ៖
"ការិយាល័យសហព្រះរាជអាជ្ញា ត្រូវធ្វើសកម្មភាពដោយឯករាជ្យនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ។សមាសភាពរបស់ការិយាល័យនេះរួមមានសហព្រះរាជអាជ្ញា និងមន្ត្រីដទៃទៀតតាមការចាំបាច់ [... ] ។ ដើម្បីអនុវត្តតាមស្មារតីនៃមាត្រា២២ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក សហព្រះរាជអាជ្ញា អាចជ្រើសរើសព្រះរាជអាជ្ញារងក្នុងចំណោមសហព្រះរាជអាជ្ញារង និងជំនួយការសហព្រះរាជអាជ្ញា ។ "

៥. វិធាន១៣(៤)នៃវិធានផ្ទៃក្នុង ចែងដូចតទៅនេះ៖
"វៀរលែងតែកិច្ចការណាដែលច្បាប់ស្តីពី អ.វ.ត.ក និងវិធានផ្ទៃក្នុងនេះតម្រូវឲ្យសហព្រះរាជអាជ្ញាអនុវត្តដោយខ្លួនឯងផ្ទាល់ សហព្រះរាជអាជ្ញាអាចផ្ទេរភារកិច្ចរបស់ខ្លួនដោយផ្ទាល់មាត់ ឬជាលាយល័ក្ខអក្សរ ដូចខាងក្រោមនេះ៖ [... ]
ខ) នៅគ្រប់ពេលវេលាទាំងអស់: ផ្ទេរភារកិច្ចទៅឲ្យព្រះរាជអាជ្ញារង ។

## ការវែកញែករកហេតុផល

៦. សហព្រះរាជអាជ្ញា សូមស្នើដាក់ជូនថា អត្ថន័យនៃច្បាប់នេះគឺមានលក្ខណៈច្បាស់លាស់ ។

៧. ក្នុងការជួយដល់ព្រះរាជអាជ្ញាក្នុងការធ្វើការចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក សហព្រះរាជអាជ្ញាម្នាក់ៗមានសិទ្ធជ្រើសរើសព្រះរាជអាជ្ញារងមួយរូប ឬច្រើនរូប (មាត្រា២២ នៃច្បាប់ស្តីពី អ.វ.ត.ក) ។ ការបើកធ្វើការតស៊ូមតិដោយផ្ទាល់មាត់នៅចំពោះមុខ អ.វ.ត.ក គឺមិនមែនជាភារកិច្ចណាមួយដែលបានចែងនៅក្នុងច្បាប់ស្តីពី អ.វ.ត.ក ឬក្នុងវិធានផ្ទៃក្នុង

---

[2] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក- ឯកសារតុលាការ ។

ដែលសហព្រះរាជអាជ្ញាត្រូវតែអនុវត្តដោយផ្ទាល់ដោយខ្លួនឯងនោះទេ[3] ។ ដូចនេះ សិទ្ធរបស់សហព្រះរាជអាជ្ញា ក្នុងការបើកធ្វើការតស៊ូមតិដោយផ្ទាល់មាត់គឺជាភារកិច្ចដែលអាចផ្ទេរប្រគល់ (ធ្វើប្រតិភូកម្ម) (វិធាន១៣(៤) នៃវិធានផ្ទៃក្នុង) ទៅឲ្យព្រះរាជអាជ្ញារងរបស់ខ្លួនបាន ។ សហព្រះរាជអាជ្ញារងទាំងនោះអាចនឹងជ្រើសរើសពីក្នុងចំណោមសហព្រះរាជអាជ្ញារងនិងពីក្នុងចំណោមជំនួយការសហព្រះរាជអាជ្ញាក៏បាន (វិធាន១៣(១) នៃវិធានផ្ទៃក្នុង)។ ដោយហេតុនេះសិទ្ធរបស់សហព្រះរាជអាជ្ញាក្នុងការតស៊ូមតិដោយផ្ទាល់មាត់អាចនឹងត្រូវបើកធ្វើដោយសហព្រះរាជអាជ្ញារងទាំងពីរក៏បាន និងដោយជំនួយការសហព្រះជអាជ្ញាក៏បាន ។ ដោយសារការិយាល័យនៃសហព្រះរាជូអាជ្ញាគឺជាការិយាល័យមួយឯករាជ្យនៅក្នុងរង្វង់ អ.វ.ត.ក. នោះ គឺមិនចាំបាច់តម្រូវឲ្យមានការអនុញ្ញាតច្បាប់ ឬសុំច្បាប់អនុញ្ញាតក្នុងការផ្ទេរប្រគល់(ធ្វើប្រតិភូកម្ម) សិទ្ធិអំណាចនោះទេ។

៨. ការផ្ទេរប្រគល់សិទ្ធិ(ធ្វើប្រតិភូកម្ម) សិទ្ធអំណាចរបស់សហព្រះរាជអាជ្ញា គឺជាតម្រូវការចាំបាច់មួយដើម្បីឲ្យដំណើរការការងាររបស់ការិយាល័យសហព្រះរាជអាជ្ញាប្រកបទៅដោយប្រសិទ្ធភាព ។ ទាំងនៅក្នុងច្បាប់ស្តីពី អ.វ.ត.ក ទាំងនៅក្នុងវិធានផ្ទៃក្នុងបានចែងថាសហព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ប្រហែលជាមិនអាចនឹងបើកធ្វើរាល់ការងារនិមួយៗក្នុងការចោទប្រកាន់ដោយខ្លួនឯងផ្ទាល់បានទេ ។ ជាពិសេសករណ៍នេះគឺតែវាដូច្នេះឯងនៅក្នុងករណីនៃការតស៊ូមតិដោយផ្ទាល់មាត់ក្នុងពេលសវនាការរបស់តុលាការ ។ នឹងមានការបើកធ្វើសវនាការជាច្រើនណាស់នៅចំពោះមុខ អ.វ.ត.ក ។ រាល់គ្រប់សវនាការដោយផ្ទាល់មាត់ទាំងអស់គឺមិនអាចនឹងត្រូវបានធ្វើឡើងតែដោយសហព្រះរាជអាជ្ញាទាំងពីររូប និងសហព្រះរាជអាជ្ញារងទាំងពីររូបដោយឯកឯងបានទេ ជាពិសេសគឺនៅពេល

---

[3] អំណាចក្នុងការធ្វើការចោទប្រកាន់ដែលត្រូវអនុវត្តដោយសហព្រះរាជអាជ្ញាដោយផ្ទាល់: ការចេញដីកាបង្គាប់អំពីវិធានការដោយបង្ខំ នៅក្នុងពេលស៊ើបអង្កេតបឋម (វិធាន១៣(៤).ក នៃវិធានផ្ទៃក្នុង) និង ការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែលតម្រូវឲ្យមានការចុះហត្ថលេខាពីសហព្រះរាជអាជ្ញាទាំងពីរ(វិធាន៥៣.១ នៃវិធានផ្ទៃក្នុង)។

00152595



ដែលអាចនឹងមានការត្រូវបើកធ្វើសវនាការច្រើនលើសពីមួយទន្ទឹមគ្នានៅក្នុងអង្គជំនុំជម្រះផ្សេងៗពីគ្នា នៅក្នុង អ.វ.ត.ក ។

៩. ព្រះរាជអាជ្ញារង និងជំនួយការសហព្រះរាជអាជ្ញាទាំងឡាយ បានមានវត្តមាននៅក្នុងអង្គសវនាការនានា នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយហេតុដូចនេះគឺជាក្រុមប្រឹក្សាកំណត់ហេតុ ។ ក្នុងនាមជាអ្នកតំណាងដែលមានការអនុញ្ញាតពីសហព្រះរាជអាជ្ញា ទាំងព្រះរាជអាជ្ញារង ទាំងជំនួយការសហព្រះរាជអាជ្ញាបានចូលរួមយ៉ាងពេញលេញនៅក្នុងសវនាការស៊ើបសួរកន្លងមក ដែលរួមមានការថ្លែងទៅកាន់សហចៅក្រមស៊ើបអង្កេតស្ដីពីបញ្ហាច្បាប់ អង្គហេតុ និងនីតិវិធី និងចោទសួរសំនួរផ្សេងៗអំពីជនត្រូវចោទ ។

១០. ការិយាល័យសហព្រះរាជអាជ្ញានៅឯ អ.វ.ត.ក ប្រតិបត្តិការក្នុងនាមជា "ការិយាល័យឯករាជ្យមួយ នៅក្នុងរង្វង់ អ.វ.ត.ក " (វិធាន១៣(១) នៃវិធានផ្ទៃក្នុង) ។ ក្នុងមាត្រា១៩ នៃច្បាប់ស្តីពី អ.វ.ត.ក ដែលចែងថា "ការិយាល័យសហព្រះរាជអាជ្ញា ត្រូវឯករាជ្យនៅក្នុងការបំពេញមុខងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយផ្សេងទៀតឡើយ ។ អាស្រ័យហេតុនេះ លុះត្រាតែច្បាប់បានចែងកំរិតផ្សេងពីនេះ សហព្រះរាជអាជ្ញាត្រូវមានឆន្ទានុសិទ្ធិពេញលេញក្នុងការផ្ទេរភារកិច្ចរបស់ខ្លួន ។ ភារកិច្ចដ៏ពេញលេញនេះ គឺលាតសន្ធឹងរហូតដល់កំណត់អំពីថាតើព្រះរាជអាជ្ញារង និង ជំនួយការសហព្រះរាជអាជ្ញាណាខ្លះដែលអាចមានសិទ្ធិអំណាចរបស់ខ្លួនក្នុងការបើកធ្វើការតស៊ូមតិដោយផ្ទាល់មាត់នៅក្នុងតុលាការបាន។

១១. នៅក្នុងគ្រប់បណ្តាតុលាការអន្តរជាតិត្រូវបានទទួលស្គាល់ និងតុលាការអន្តរជាតិតូបនីយកម្មនានាទាំងអស់ថា មុខងាររបស់ព្រះរាជអាជ្ញានឹងត្រូវបានផ្ទេរប្រគល់ទៅឱ្យមន្ត្រីរបស់ខ្លួនដែលមានលក្ខណ:សម្បត្តិសមស្រប ។ តុលាការ*ពិសេស* សម្រាប់អតីតប្រទេសយូហ្គោស្លាវី និង ប្រទេសរ្វ៉ាន់ដា តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិនៅទីក្រុងឡាអេ តុលាការកូនកាត់នៅកូសូវ៉ូ ទីម័រខាងកើត និងអង្គជំនុំជម្រះពិសេសសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាមដែលជួយឧបត្ថម្ភដោយអន្តរជាតិនៅក្នុងតុលាការ បូស្នៀអ៊ែរហ្សេហ្គោវីនទាំងអស់នេះគេសុទ្ធតែមានអគ្គរដ្ឋអាជ្ញាជាន់ខ្ពស់មួយរូបៗរបស់គេ តែគេក៏មាន

00152596



រដ្ឋអាជ្ញារង និងជំនួយការរដ្ឋអាជ្ញាជាច្រើនរូបដែរ (អគ្គរដ្ឋអាជ្ញាសម្រាប់ការជំនុំជម្រះក្តី និងរដ្ឋអាជ្ញាសម្រាប់ការជំនុំជម្រះក្តី) ដែលមានសិទ្ធពេញលេញក្នុងការធ្វើសវនាការដើម្បីចូលរួមនៅក្នុងអង្គសវនាការនានារបស់តុលាការ ។ ”

សូមដាក់ជូនដោយសេចក្តីគោរពអំពីយើងខ្ញុំ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧

CO-PROSECUTORS CO-PROCUREURS * E.C.C.C * C.E.T.C *

លោកស្រី ជា លាង លោក Robert PETIT